ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ឃែរី វើលដ៍ប្រ៊ីដ ឡូជីស្ទីក

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស ឃែរី ទើលដ៍ប្រ៊ីដ ឡូជីស្ទីក** ( **KERRY WORLDBRIDGE LOGISTICS SEZ** ) ដែលមានទីតាំងស្ថិតនៅភូមិដីណាក់សង្កែ និងភូមិព្រៃករទាំង សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស ឃែរី ទើលដ៍ប្រ៊ីដ ឡូជីស្ទីក** មានទំហំ ៦៣០,៤៣០ ម២ (ប្រាំមួយរយសាមសិបពាន់បួនរយសាមសិបម៉ែត្រក្រឡា) ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ឃែរី ទើលដ៍ប្រ៊ីដ ឡូជីស្ទីក** ដូចមានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស ឃែរី ទើលដ៍ប្រ៊ីដ ឡូជីស្ទីក** នេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងក្រុមហ៊ុន យៃរី វើលដ៏ប្រ៊ីដ ឡូជីស្ទីក លីមីធីត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងខ្លួន។ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្ដាសោភា**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ